ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល

លេខៈ ០២៣ ជ.ប.ក/អ.រ.ប

ថ្ងៃ[illegible]ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០

នាយកដ្ឋានបណ្ដុះបណ្ដាល
ចូល
លេខ 096/20 ម៉ោង 3:30
ថ្ងៃទី10 ខែ03 ឆ្នាំ2020
បញ្ជូន.............................

# របាយការណ៍

## ស្ដីពី

## សកម្មភាព និងលទ្ធផលការងារប្រចាំខែកុម្ភៈ និងទិសដៅបន្ត សម្រាប់ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-សកម្មភាពការងារ និងលទ្ធផល

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមក ពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃ សរុបចំនួន ១.០៤១ច្បាប់ និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៥៤៧ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៤២ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៦១ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ៥៨ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៦០ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ១៧៣ច្បាប់។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមានចំនួន ៥១១ច្បាប់ ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ១៧៧ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ២០ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៤៦ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ៥៦ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៤៤ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៦៨ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន ៣៦៩ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ១១២ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១០ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១២៦ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ៤០ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២៥ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៥៦ច្បាប់។

-បានទទួលឯកសារចំនួន២០៦ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **៣៧ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **០៧ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៦៦ច្បាប់** នាយកដ្ឋានបណ្តុះបណ្តាលចំនួន **៣៦ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **២០ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤០ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន **៩២ច្បាប់** ក្នុងនោះ លិខិតបង្គាប់ការចំនួន **៤២ច្បាប់** និងលិខិតបញ្ជាបេសកកម្មចំនួន **៥០ច្បាប់** ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា។

ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្តដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ **អគ្គនាយកដ្ឋានរដ្ឋបាល** បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត វេទិកា ជាវគ្គិន និងកម្មវិធីនានាដូចខាងក្រោម៖

-ចូលរួមជាមួយ**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម **Saud F.M.AI Suwelim** ឯកអគ្គរដ្ឋទូតអារ៉ាប៊ីសាអូឌីត ចូលជួបសម្តែងការគួរសម

- ការប្រជុំ សិក្ខាសាលា៖

-ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការរៀបចំប្រកាសដាក់ឱ្យដំណើរការរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-ដឹកនាំការសម្ភាសន៍ជ្រើសរើសទីប្រឹក្សារបស់គម្រោង LEAP

-រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីសំណើសុំគោលការណ៍ជ្រើសរើសក្របខណ្ឌមន្ត្រីពន្ធនាគារថ្មីចំនួន ៤៥៥រូប សម្រាប់ឆ្នាំ២០២០-២០២១ ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ

-រៀបចំកិច្ចប្រជុំពិភាក្សាលើកិច្ចការកែសម្រួលតួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន

-ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសកម្មភាពជនពិការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំបន្តដើម្បីពិគ្រោះយោបល់លើសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-ចូលរួមកិច្ចប្រជុំពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសាយភាយហិរញ្ញប្បទានអាវុធមហាប្រល័យ

-ចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី ស្ថិតក្នុងស្រុកកោះធំ ខេត្តកណ្តាល

-ចូលរួមកិច្ចប្រជុំឆ្លងសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ព្រមទាំងឯកសារសម្រាប់អង្គសន្និបាត

-ចូលរួមកិច្ចប្រជុំពិនិត្យសំណើគម្រោងរបស់ គ.ជ.អ.ប ដើម្បីលើកសំណើគម្រោងទៅមូលនិធិអាកាសធាតុបៃតង

-ចូលរួមកិច្ចប្រជុំពិភាក្សា ដើម្បីធ្វើអធិការកិច្ចលើលទ្ធផលការងារ នៃការអនុវត្តលើការគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាតាមអង្គភាពនានា ក្រោយពីក្រុមការងារ របស់ក្រសួងមុខងារសាធារណៈ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០២០ ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រើប្រាស់ភាសា និងអក្សរខ្មែរ នៅលើរូបសញ្ញា រៀបចំដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅរាជបណ្ឌិតសភាកម្ពុជា

-ចូលរួមកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើការរៀបចំកម្មវិធី (Software) ដើម្បីគាំទ្រដល់ការគ្រប់គ្រងសាលារៀន នៅទីស្តីការក្រសួងមុខងារសាធារណៈ

-ចូលរួមកិច្ចប្រជុំពិភាក្សា ដើម្បីពិនិត្យ និងដោះស្រាយផលប៉ះពាល់ពីការបញ្ឈប់សិទ្ធិធ្វើអាជីវកម្មភាស៊ីផ្សារចាស់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង មុនចប់អាណត្តិកិច្ចសន្យារបស់អ្នកវិនិយោគ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នា នៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRG-JG) នៃក្រុមការងារហិរញ្ញវត្ថុ FATF

-ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង ដើម្បីអនុវត្តអនុក្រឹត្យ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលឱ្យទៅរដ្ឋបាលរាជធានី ខេត្ត

-ចូលរួមកិច្ចប្រជុំជាមួយអង្គការតស៊ូមតិ និងគោលនយោបាយ(API) និងអង្គការ Instedd អំពីការសិក្សាដើមគ្រាពាក់ព័ន្ធនឹងការយល់ដឹងក៏ដូចជាការប្រើប្រាស់សេវាការិយាល័យច្រកចេញចូលតែមួយរបស់ប្រជាពលរដ្ឋនៅស្រុកគោលដៅចំនួន០៥ នៃខេត្តបាត់ដំបង

-ចូលរួមកិច្ចប្រជុំរៀបចំអនុវត្តនីតិវិធី នៃការដោះដូរទីតាំង និងអគាររបស់មណ្ឌលសុខភាពប៉ោយប៉ែត១ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

-ចូលរួមកិច្ចប្រជុំជាមួយអង្គការតម្លាភាព ដើម្បីស្នើសុំការគាំទ្រលើការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី "សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ២០២១-២០៣០ និងសេចក្តីព្រាងបឋមផែនការយុទ្ធសាស្ត្រគណៈកម្មការទន្លេមេគង្គ២០២១-២០២៥" នៅខេត្តសៀមរាប រៀបចំដោយគណៈកម្មការទន្លេមេគង្គ

-ចូលរួមកិច្ចប្រជុំគណៈកម្មការដឹកនាំការអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ រៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា

-ចូលរួមកិច្ចប្រជុំលើកទី១ នៃក្រុមការងារផ្នែកទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ របស់កម្មវិធី ACCESS ដែលរៀបចំដោយក្រសួងកិច្ចការនារី

-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសកំណែទម្រង់ព្រៃឈើលើកទី៥០ រៀបចំដោយរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

-ចូលរួមកិច្ចប្រជុំស្តីពីសំណើសុំកែសម្រួលតារាងតម្លៃសៀវភៅបន្ទុកភាស៊ីកំពង់ចម្លង ក្នុងខេត្តកំពង់ចាម នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើឯកសារទស្សនទានសំខាន់ៗ និងសេចក្តីសង្ខេបយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (២០១៩-២០២៣) នៅទីស្តីការគណៈរដ្ឋមន្ត្រី រៀបចំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-ចូលរួមសិក្ខាសាលាស្តីពី "ការអនុវត្តន៍កម្មវិធីកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងវិស័យចំណីអាហារ និង ឱសថ"

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីព្រាងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តន៍យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ រៀបចំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមសិក្ខាសាលាស្តីពី "នីតិវិធីលទ្ធផលកម្មសាធារណៈ និងការអនុវត្តផែនការសកម្មភាពលម្អិត MAP3 សម្រាប់ឆ្នាំ២០២០" រៀបចំដោយអគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ នៅខេត្តសៀមរាប

-ចូលរួមសិក្ខាសាលាពិភាក្សា និងរៀបចំវគ្គសម្របសម្រួលសម្រាប់រដ្ឋបាលថ្នាក់ ក្រោមជាតិ នៃកម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ដែលរៀបចំដោយអង្គការ WaterSHED និងអង្គការ WaterAid នៅខេត្តសៀមរាប

-ចូលរួមសិក្ខាសាលាជាតិស្ដីពីការលើកកម្ពស់សមត្ថភាពស្ថាប័ន សម្រាប់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ រៀបចំដោយក្រសួងផែនការ នៅរាជធានីភ្នំពេញ

-ចូលរួមសិក្ខាសាលាស្ដីពី ពិធីបើកឱ្យដំណើរការអនុវត្តគម្រោងជំរុញការចូលរួមរបស់យុវជនក្នុងដំណើរការកសាងផែនការ និងថវិកានៅកម្រិតមូលដ្ឋាន នៅខេត្តសៀមរាប

-ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្ដីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ

-ចូលរួមសិក្ខាសាលាកែសម្រួលឯកសារបណ្ដុះបណ្ដាលស្ដីពីភាពជាអ្នកដឹកនាំ នៅសណ្ឋាគារអង្គរ នៅខេត្តសៀមរាប

-ចូលរួមសិក្ខាសាលាស្ដីពីលទ្ធផលនៃការសិក្សាលម្អិតអំពីដំណើរការទទួល និងសម្រុះសម្រួលដោះស្រាយបណ្ដឹងតវ៉ារបស់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលក្រុង ស្រុកនៃខេត្តបាត់ដំបង និងនៅរដ្ឋបាលក្រុងកំពង់ឆ្នាំង នៅសណ្ឋាគារ យើងហ៊ួ ខេត្តបាត់ដំបង

-ចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារកម្មវិធីសហាតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីផ្ដល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ហៅកាត់ថា "ACCESS"។

▪ **កម្មវិធីផ្សេងៗ៖**

-រៀបចំវេទិកាស្ដីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤ នៅសាលប្រជុំទីស្ដីការក្រសួងមហាផ្ទៃ

-ចូលរួមសន្និសីទស្ដីពី "ការពង្រឹងភាពជាអ្នកដឹកនាំ ដើម្បីដឹកនាំការកែទម្រង់" (Symposium on mpowering Leadeship to Lead Reform) ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ

-ចូលរួមសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ

-ចូលរួមសន្និបាតប្រចាំឆ្នាំលើកទី១៧ របស់សមាគមម៉ូស្លីមអះម៉ាឌីយ៉ាកម្ពុជា នៅខេត្តកំពង់ឆ្នាំង

-ចូលរួមប្រារព្ធពិធីបុណ្យមាឃបូជា នៅបរិវេណឧបដ្ឋានសាលាមុខព្រះសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង) ស្រុកពញាឮ ខេត្តកណ្ដាល

-ចូលរួមក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល ដើម្បីត្រៀមរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស

-ចូលរួមវគ្គបណ្ដុះបណ្ដាលថ្នាក់ជាតិស្ដីពី ការប្រើឧបករណ៍ប៉ាន់ប្រមាណហានិភ័យសម្រាប់រៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នជាតិ រៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-ចូលរួមវេទិការ "ASEAN Sustainable Urbanisation Strategy (ASUS) Socailisation Forum for Cities" នៅប្រទេឥណ្ឌូនេស៊ី

-ចូលរួមវេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៧១នៅទីស្ដីការគណៈរដ្ឋមន្ត្រី រៀបចំដោយក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-ចូលរួមវេទិកាស្ដីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤ នៅទីស្ដីការក្រសួងមហាផ្ទៃ

-ជួបសម្ភាសន៍ជាមួយក្រុមការងារវាយតម្លៃពាក់កណ្ដាលអាណត្តិរបស់គម្រោងអភិវឌ្ឍន៍សមត្ថភាពក្នុងការគ្រប់គ្រងការបណ្ដុះបណ្ដាលសម្រាប់ការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ

-ចូលរួមទទួលគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ចូលរួមជាវាគ្មិនកិត្តិយសនៅក្នុងកម្មវិធីសន្ទនាមតិ "ជីវិតយើងសង្គមយើង"។

**៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង**

**៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន (គ្មាន)**

**៤.១.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង ចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការបែងចែកចំណូល កម្រៃសេវារដ្ឋបាលនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសការិយាល័យច្រកចេញចូលតែមួយដែលមានស្នាដៃល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងគំរូដីកាស្តីពីការផ្ទេរប្រតិភូកម្មមុខងារក្នុងវិស័យនានាទៅឱ្យរដ្ឋបាលខណ្ឌទាំងអស់ នៃរាជធានីភ្នំពេញ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី"កិច្ចការរដ្ឋបាល"សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

**៤.២.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន**

អនុក្រឹត្យលេខ២៤៩អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំក្នុងគ្រួសារក្រីក្រ។

**៤.២.២-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពី ការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០។

## ៥-ការងារបុគ្គលិក

### ៥.១-ការងារក្របខ័ណ្ឌ

គិតត្រឹមខែកុម្ភៈឆ្នាំ២០២០ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ សរុបមានចំនួន ១៣.៣៤៩រូប/ស្រី៣.៤៤៦រូប (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ១.០០៦រូប/ស្រី២៤២រូប ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ៩.២១៣រូប/ស្រី២.៧៣៨រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន ១.១៧៦រូប/ស្រី១៩០រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន ១.៩៥៤រូប/ស្រី២៧៦រូប) បើប្រៀបធៀបទៅនឹងខែមករា ឆ្នាំ២០២០ ក្របខ័ណ្ឌកើនឡើងចំនួន ០៨រូប/ស្រី០៥រូប។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃ ក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ១៥រូប/ស្រី០៦រូប(ក្នុងនោះ ផ្ទេរចូលពីក្របខណ្ឌក្រសួងនានាចំនួន ១០រូប/ស្រី០៤រូប និងបញ្ចូលទីប្រឹក្សា និងមន្ត្រីជាប់កិច្ចសន្យា នៃលេខាធិការដ្ឋានគ.ជ.អ.ប ចំនួន ០៥រូប/ស្រី០២រូប) ក្របខ័ណ្ឌចេញចំនួន ០៧រូប/ស្រី០១រូប (ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន ០៤រូប/ស្រី០១រូប លុបឈ្មោះដោយមរណៈភាពចំនួន០២រូប និងលុបឈ្មោះដោយលាឈប់ពីការងាររដ្ឋចំនួន ០១រូប)។

### ៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារ និងចូលបម្រើការងារវិញសរុបចំនួន ០៥រូប/ស្រី០៣រូប(ក្នុងនោះឈប់សម្រាកលំហែមាតុភាពចំនួន ០៣រូប និងសុំចូលបម្រើការងារក្នុងអង្គភាពវិញបន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ០២រូប)។ ទន្ទឹមនោះថ្នាក់ដឹកនាំក្រសួងក៏បានផ្ដល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការស៊ីវិល នៅរដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន ២៤៧គ្រឿង ក្នុងនោះ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំនួន ៤៦គ្រឿងរួមមានៈ(ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៩គ្រឿង ថ្នាក់មហាសេនាចំនួន ១១គ្រឿង ថ្នាក់ ធិបឌិន្ទចំនួន ០២គ្រឿង ថ្នាក់សេនាចំនួន ១០គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន១៤គ្រឿង) គ្រឿងឥស្សរិយយសុវត្ថារាថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៤គ្រឿង គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌតាមលំដាប់ថ្នាក់ ចំនួន ០៨គ្រឿងរួមមានៈ(ថ្នាក់សេនា ចំនួន០១គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ០៧គ្រឿង) និងមេដាយការងារតាមលំដាប់ថ្នាក់ចំនួន ១៨៩គ្រឿងរួមមានៈ( ថ្នាក់មាស ចំនួន២៤គ្រឿង ថ្នាក់ប្រាក់ចំនួន៣០គ្រឿង ថ្នាក់សំរឹទ្ធចំនួន១៣៥គ្រឿង)។ជាមួយគ្នានេះដែរក្រសួងមហាផ្ទៃក៏បានផ្ដល់ប័ណ្ណសម្គាល់ខ្លួនជូនសមាជិកក្រុមប្រឹក្សាខេត្ត មន្ត្រីរាជការ និងបណ្ណ័សម្រាប់ចេញ-ចូលក្រសួងចំនួន ១១០រូប/ស្រី២៩រូប។

### ៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

ក្នុងខែកុម្ភៈ ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន១.០០៦រូប/ស្រី២៤២រូប ស្មើនឹង ២៤.០៥% ដែលក្នុងនោះរួមមាន ៖

-មន្ត្រីរាជការស៊ីវិលចំនួន ៩៨៨រូប/ស្រី ២៤១រូប ស្មើនឹង ២៤,៣៩% ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន ០៣រូប អនុរដ្ឋលេខាធិការចំនួន ០៣រូប/ស្រី០១រូប អគ្គនាយកចំនួន ០១រូប អគ្គនាយករងចំនួន ២៧រូប/ស្រី០២រូ អគ្គលេខាធិការរងចំនួន ០៤រូប/ស្រី០១រូប គណៈកម្មាធិការ គ.ជ.ប.ទ ចំនួន ០៣រូប (ក្នុងនោះសមាជិកគណៈកម្មធិការចំនួន ០១រូប ប្រធានលេខាធិការចំនួន ០១រូប អនុប្រធានលេខាធិការចំនួន០១រូប ) ក្រុមប្រឹក្សានីតិកម្មចំនួន ០៧រូប/ស្រី ០២រូប (ក្នុងនោះប្រធានចំនួន ០១រូប អនុប្រធានចំនួន ០៣រូប/ស្រី០១រូប សមាជិកចំនួន ០៣រូប/ស្រី០១រូប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគ.ជ.អ.បចំនួន ១៧រូប/ស្រី០៦រូបអគ្គាធិការចំនួន ០១រូប អគ្គាធិការរងចំនួន ០៥រូប/ស្រី ០១រូប ប្រធាននាយកដ្ឋានចំនួន ១២រូប/ស្រី០១រូប អនុប្រធាននាយកដ្ឋានចំនួន ១៧០រូប/ស្រី២៩រូប ប្រធានការិយាល័យចំនួន ៨២រូប/ស្រី១៩រូប អនុប្រធានការិយាល័យចំនួន២៤៤រូប/ស្រី ៧១រូប និងមន្ត្រីចំនួន ៤០៥រូប/ស្រី ១១៣រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្ដីការក្រសួងចំនួន ១៨រូប/ស្រី០២រូប ស្មើនឹង១១,១១%

-មន្ត្រីរាជការក្របខ័ណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន ៥២៩រូប/ស្រី៥២រូប ស្មើនឹង ៩,៨២%។ ដោយឡែកក្នុងខែកុម្ភៈឆ្នាំ២០២០នេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការ ជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន ២៧រូប/ស្រី០៤រូប។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែកុម្ភៈឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន**១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២%** ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន **២៥រូប/ស្រី០១រូប** អភិបាលរងរាជធានី ខេត្តចំនួន **១៥០រូប/ស្រី២៦រូប**)

-គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន**៩៣៨រូប/ស្រី១៩៨រូប ស្មើនឹង២១.១១%** ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន **២០៣រូប/ស្រី០៧រូប** អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន **៧៣៥រូប/ស្រី ១៩១រូប**)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន **៦.៤៨៩រូប/ស្រី ២.១៥២រូប ស្មើនឹង ៣៣.១៦%** ក្នុងនោះ(សាលារាជធានី ខេត្តចំនួន **២.៨០៩រូប/ស្រី៩១៥រូប ស្មើនឹង ៣២.៥៧%** សាលាក្រុង ស្រុក ខណ្ឌចំនួន **៣.៦៨០រូប/ស្រី១.២៣៧រូប ស្មើនឹង ៣៣,៦១%**) និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន **៥៤រូប** ។ ទន្ទឹមនេះដែររាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃក៏បានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ចជូនអភិបាល អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្លាស់ប្តូរភារកិច្ច និងតែងតាំងស្មៀនឃុំ សង្កាត់សរុបចំនួន **១៨រូប/ស្រី០៥រូប** (**ដូចក្នុងឧបសម្ព័ន្ធ១ក-១ឃ**)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាពបច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន **៥៥៩រូប/ស្រី ៩៥រូប** (**ស្មើនឹង ១៦,៩៩%**) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន **២៥រូប** សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន **៥៣៤រូប/ស្រី ៩៥រូប**)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន **៣.៥៥៥រូប/ស្រី៦២១រូប** (**ស្មើនឹង១៧,៤៩%**)ក្នុងនោះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **២០៣រូប/ស្រី០៥រូប** សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **៣.៣៥២រូប/ស្រី៦១៦រូប**។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន **១១.៥៧២រូប/ស្រី២.៣៧៦រូប**(**ស្មើនឹង២០.៥៣%**)(ក្នុងនោះ មេឃុំចំនួន **១.៤០៥រូប/ស្រី១១០រូប** ចៅសង្កាត់ចំនួន **២៤១រូប/ស្រី២៦រូប** ជំទប់ទី១ចំនួន **១.៣៥៤រូប/ស្រី២២០រូប** ជំទប់ទី២ចំនួន **១.៤០៥រូប/ស្រី៣០៥រូប** ចៅសង្កាត់រងទី១ ចំនួន **២៤១រូប/ស្រី ៦០រូប** ចៅសង្កាត់រងទី២ចំនួន **២៤១រូប/ស្រី៥៣រូប** និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន **៦.៦៣៤រូប/ស្រី១.៥៩៤រូប**)។ ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះក្រសួងមហាផ្ទៃបានផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចំនួន **២៩រូប/ស្រី០៣រូប** ក្នុងនោះសមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន **០៤រូប**/(**ដូចក្នុងឧបសម្ព័ន្ធ២ក**) សមាសភាពសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **០៤រូប/ស្រី០១រូប** (**ដូចក្នុងឧបសម្ព័ន្ធ២ខ**) និង សមាសភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ចំនួន **២៣រូប/ស្រី០២រូប**(**ដូចក្នុងឧបសម្ព័ន្ធ២គ**)។

**៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ៩.៨៥៨រូប/ស្រី ២.៧៧៦រូប(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៨៨៨រូប/ស្រី ២០១រូប និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន ៨.៩៧០រូប/ស្រី២.៥៧៥រូប)។ ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើលិខិតជូនដំណឹងទៅគ្រប់អង្គភាពចំណុះទីស្តីការក្រសួងស្តីពីការបំពេញប្រវត្តិរូបមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០២០ និងបានធ្វើបច្ចុប្បន្នភាពរួចរាល់ចំពោះគណៈអភិបាលខេត្ត ក្រុង ស្រុកចំនួន ០៣ខេត្ត គឺខេត្តប៉ៃលិន ខេត្តមណ្ឌលគិរី និងខេត្តកោះកុង។

**៦-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន០២វគ្គដែលមានសិក្ខាកាមចូលរួមសរុប ចំនួន១៦២រូប/ស្រី២១រូប និងរៀបចំសិក្ខាសាលាបានចំនួន០២លើក ដែលមានសិក្ខាសរុបចំនួន ៤៨រូប/ស្រី១៣រូប ដូចខាងក្រោម៖

-វគ្គបណ្តុះបណ្តាលស្តីពីលេខាធិការរដ្ឋបាល សម្រាប់ក្រុមគោលដៅជាមន្ត្រីក្របខ័ណ្ឌ(គ)ដែលកំពុងបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដែលមានសិក្ខាកាមចូលរួមសរុប **២៦រូប/ស្រី០៧រូប**

-វគ្គបណ្តុះបណ្តាលស្តីពីគ្រូបង្គោលសម្រាប់វគ្គតម្រង់ទិសស្តីពី ការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន **១៣៦រូប/ស្រី១៤រូប** នៅខេត្តកំពង់ចាម។

-បានរៀបចំសិក្ខាសាលាកែសម្រួលឯកសារបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ដោយសហការជាមួយអង្គការវ៉ៃធឺសេដ(Water SHED)ដែលមានសិក្ខាកាមចូលរួមសរុប ២៨រូប (ស្រី០៩រូប) នៅខេត្តសៀមរាប

-បានរៀបចំសិក្ខាសាលាវិបស្សនា កែសម្រួលបញ្ចប់ឯកសារបណ្តុះបណ្តាលវគ្គតម្រង់ទិស សម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានសិក្ខាកាមចូលរួមសរុប ២០រូប(ស្រី០៤រូប)នៅខេត្តកំពត។

**៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រី **១១រូប** ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិស័យទេសចរណ៍ឆ្នាំ២០២០ នៅខេត្តយ៉ុងគី នៃសាធារណរដ្ឋកូរ៉េ។

**៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ**

ចំពោះការងារព័ត៌មាន និងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាលបាន និងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រត្រីមាសិក និងវិសាមញ្ញការលេខ០៤,បន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដោយបានបញ្ចូលអត្ថបទចំនួន **១៣ករណី** និងបានបន្តរៀបចំចាត់ចែងចងក្រងឯកសារដើម្បីបង្ហោះក្នុងTelegram Channel របស់អគ្គនាយកដ្ឋានរដ្ឋបាល។ លើសពីនេះ ក៏បានផ្សព្វផ្សាយសេចក្តីជូនដំណឹងមួយចំនួនដូចខាងក្រោម៖

-ស្តីពីកម្មវិធីអាហារូបករណ៍ និងការផ្លាស់ប្តូរការអប់រំសម្រាប់ការអភិវឌ្ឍ ( Scholarships and Education - Exchanges for Development-SEED) ទៅសិក្សារយៈពេលខ្លីនៅប្រទេសកាណាដាសម្រាប់ឆ្នាំសិក្សា២០២០-២០២១

-ស្តីពីការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត និងថ្នាក់វេជ្ជសាស្ត្រទូទៅ ទៅសិក្សានៅសាធារណរដ្ឋអាស៊ែបៃហ្សង់ក្នុងឆ្នាំសិក្សា២០២០-២០២១

-ស្តីពីការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ទៅសិក្សានៅព្រះរាជាណាចក្រថៃ សម្រាប់ឆ្នាំសិក្សា២០២០-២០២១

-ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ស្រាវជ្រាវរយៈពេលខ្លីទៅសិក្សានៅ Chey Institute for Advanced Studies នៃសាធារណរដ្ឋកូរ៉េសម្រាប់ឆ្នាំសិក្សា២០២០-២០២១។

**៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃ ជម្រាបជូនទៅក្រសួង ស្ថាប័ន និងបានដាក់ចេញនូវគោលការណ៍ណែនាំដល់រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពចំណុះក្រសួង ដូចខាងក្រោម៖

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ករណីឈ្មោះ Kun Krishna ផ្ញើសារចូលគេហទំព័រហ្វេសប៊ុករបស់សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងបទល្មើសព្រៃឈើរបស់ឯកឧត្តម ស្វាយ សំអ៊ាង អភិបាលខេត្តមណ្ឌលគិរី។

-រដ្ឋបាលរាជធានីភ្នំពេញ ករណី ឈ្មោះ សាម សំណាង, ម៉ៅ ពៅ, ម៉ៅ សារឿន, គាន បុប្ផា, ជា សំអូន, អ៊ុច ពន្លក, ឈិត សុឃឿន និងឈ្មោះ ប៊ុន សុខា ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីចេញប័ណ្ណកម្មសិទ្ធិរបស់ប្រជាពលរដ្ឋចំនួន ០៨គ្រួសារ រស់នៅផ្លូវលេខ ១៨០០ ក្រុមទី៣ ភូមិទួលពពែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

•តំណាងប្រជាពលរដ្ឋ ២៥គ្រួសារ ស្នើសុំអន្តរាគមន៍ទប់ស្កាត់ឈ្មោះ វ៉ន់ ណូ បច្ចុប្បន្នជាមេឃុំអណ្តូងថ្ម ឱ្យបញ្ឈប់ធ្វើសកម្មភាពឈូសឆាយរំលោភយកដីរបស់ពួកគាត់ ស្ថិតនៅក្នុងភូមិត្រពាំងស្គុយ១ ភូមិត្រពាំងស្គុយ២ ភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

•តំណាងប្រជាពលរដ្ឋ និងអាជីវករ ៦២គូប នៅឆ្នេរអូត្រេះ ស្នើសុំដោះស្រាយសំណងចំពោះការខូចខាតទ្រព្យសម្បត្តិ និងមុខរបរដែលត្រូវបំផ្លាញដោយសារការឈូសឆាយរបស់រដ្ឋបាលខេត្តព្រះសីហនុ។

•តំណាងប្រជាពលរដ្ឋចំនួន ៥៨គ្រួសារ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ចាត់មន្រ្តីជំនាញចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដីទំហំ ២០៧ហិកតា ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិស្ថិតនៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

•ក្រុមហ៊ុន ខេមបូវីហ្សិន ភីភីវី ខូអិលធីឌី ផ្តល់សេចក្តីចម្លងស្តីពីបណ្តឹងជំទាស់នឹងទិន្នន័យនៃអចលវត្ថុរបស់ក្រុមហ៊ុន ខេមបូវីហ្សិន ភីភីវី ខូអិលធីឌី ដែលបានបិទផ្សាយជាសាធារណៈក្នុងឯកសារនៃការវិនិច្ឆ័យ(ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី) ស្ថិតនៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

-រដ្ឋបាលខេត្តកោះកុង ករណី៖

•តំណាងប្រជាពលរដ្ឋ ១០គ្រួសារ រស់នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង ស្នើសុំរកយុត្តិធម៌ ដោះស្រាយ និងជំរុញកឱ្យក្រុមហ៊ុន Union Development Group co.,ltd ដែលបានរំលោកបំពានយកដីចំការប្រជាពលរដ្ឋដែលបានអាស្រ័យផលតាំងពីយូរមកហើយ។

•តំណាងប្រជាពលរដ្ឋ ០៨គ្រួសារ រស់នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង ស្នើសុំរកយុត្តិធម៌ដោះស្រាយ និងជំរុញឱ្យក្រុមហ៊ុន SEZ របស់លោកឧកញ៉ា លី យ៉ុងផាត់ ដែលបានរំលោភបំពានយកដីចំការរបស់ប្រជាពលរដ្ឋដែលអាស្រ័យផលអស់រយៈពេលជាង ១០ឆ្នាំមកម្ល៉េះ។

-រដ្ឋបាលខេត្តកណ្តាល ករណីតំណាងប្រជាពលរដ្ឋចំនួន ១៤គ្រួសារ ស្នើសុំអន្តរាគមន៍ជួយដោះស្រាយទំនាស់ដីធ្លីមួយកន្លែងស្ថិតនៅភូមិសាលាតាព្រហ្ម ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណី៖

•ឈ្មោះ ង៉ាន ហ្សាវីតា សំណើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តបន្ទាយមានជ័យដើម្បីទប់ស្កាត់ឈ្មោះ ឡុង ឆេងម៉េង ធ្វើសកម្មភាពឈូសឆាយនៅលើដីរបស់គាត់ ស្ថិតនៅចំណុចបឹងជង្រុក ភូមិអូរអំពិល ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

•សកម្មភាពក្រុមអនាធិបតេយ្យរំលោភចូលរុករាន វាស់វែង បែងចែក លក់ដូរដី នៅទីតាំងដីស្ថានីយ៍ផ្សព្វផ្សាយ និងស្ពានព្រៃឈើតាបែន២ មានទីតាំងស្ថិតនៅឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តត្បូងឃ្មុំ ករណីតំណាងប្រជាពលរដ្ឋ ២៦១គ្រួសារ ស្នើសុំជួយអន្តរាគមន៍ដកហូតដីព្រៃសហគមន៍ទំហំ ១.៥៧៣,៦២ហិកតា ពីឧកញ៉ា ឆាយ ជ្រាយ, មេន ចាន់ធឿន និងក្រុមហ៊ុន ហាមីនីវីសអ៊ីនវេសមេន ស្ថិតនៅឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។

-រដ្ឋបាលខេត្តព្រៃវែង ករណីឈ្មោះ សុង យ៉េកហៀង ស្នើសុំឱ្យរដ្ឋបាលខេត្តព្រៃវែង និរាករណ៍ឯកសារប្រេឌិតលក់ដីចំណីផ្លូវជាតិលេខ៨ និងប្រគល់ដីចំណីផ្លូវជាតិដែលនៅជាប់ក្បាលដីរបស់គាត់ ដើម្បីប្រើប្រាស់ដូចប្រជាពលរដ្ឋទូទៅ ស្ថិតនៅភូមិវៃទេ ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង។

-រដ្ឋបាលខេត្តស្វាយរៀង ករណីឈ្មោះ កែវ ឆាន់ ស្នើសុំឲរដ្ឋបាលខេត្តស្វាយរៀង ធ្វើការអង្កេតស្រាវជ្រាវលើករណីការកេសាងឯកសារលោបដោយបំភ័ន្ត ដើម្បីជាមធ្យោបាយក្នុងការទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៨៣៨១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥។

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីឈ្មោះ ញ៉ែម រ៉ា ស្នើសុំឱ្យរដ្ឋបាលខេត្តមណ្ឌលគិរី ធ្វើការអង្កេត ស្រាវជ្រាវ និងផ្ទៀងផ្ទាត់រវាងឯកសារកាន់កាប់ដីរបស់ឈ្មោះ កែ ចំរើន និងការកាន់កាប់ដីជាក់ស្តែងរបស់ឈ្មោះ ញ៉ែម រ៉ា ស្ថិតនៅភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

-រដ្ឋបាលខេត្តកំពង់ធំ និងខេត្តកំពត ករណីស្តីពីលទ្ធផលនៃការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលក្នុងការិយបរិច្ឆេទ២០១៨។

-រដ្ឋបាលខេត្តប៉ៃលិន ស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវនិមិត្តសញ្ញាខេត្តប៉ៃលិន។

-សមាគមអ្នកគាំពារសុខភាពពលរដ្ឋកម្ពុជា ករណីស្នើសុំផ្ទៀលដីទំហំ ៦១៦ហិកតា ស្ថិតនៅទីតាំងចំណុចជាប់ជើងភ្នំស៊ីម៉ូលី ភូមិស្ទឹងសំរោង ឃុំអូរបាក់រទេះ ស្រុកកំពង់សិលា ខេត្តព្រះសីហនុ ចេញពីគម្របព្រៃចំរុះនៃឧទ្យានជាតិព្រះមុន្នីវង្សបូកគោ ហើយប្រគល់ដីនេះជាកម្មសិទ្ធិរបស់សមាគម ដើម្បីបង្កើត និងកសាងមជ្ឈមណ្ឌល តេជោ ហ៊ុនសែន សន្តិភាព គាំពារព្យាបាលចាស់ជរាកម្ពុជា។

**៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៩៤។ ទន្ទឹមនោះអគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើលិខិតជម្រាបទៅរដ្ឋបាលខេត្តកោះកុង ករណីគណៈកម្មការទី១ នៃព្រឹទ្ធសភាស្នើសុំអន្តរាគមន៍ពន្លឿនការសុំបំបែកភូមិ៤ ស្ថិតក្នុងសង្កាត់ដងទង់ជាពីរ និងការកំណត់ព្រំប្រទល់រដ្ឋបាលរវាងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីម៉ា ដែលស្នើសុំដោយរដ្ឋបាលខេត្តកោះកុង។

**៧.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

ក្រសួងមហាផ្ទៃបានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំគោរមងារឧកញ៉ាចំនួន ០១រូប មេដាយជាតូបការចំនួន ០១គ្រឿង មេដាយព្រះរាជាណាចក្រកម្ពុជាចំនួន ១៥គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៣គ្រឿង ថ្នាក់មហាសេនាចំនួន ០៥គ្រឿង និងថ្នាក់សេនាចំនួន ០៧គ្រឿង) មេដាយសុវត្ថារាចំនួន ៥០គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ១០គ្រឿង ថ្នាក់មហាសេនាចំនួន ២១គ្រឿង ថ្នាក់ធិបឌិនចំនួន ១៣គ្រឿង និងថ្នាក់សេនាចំនួន ០៦គ្រឿង) មេដាយមុនីសារាភ័ណ្ឌចំនួន ៥៧គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៩គ្រឿង ថ្នាក់មហាសេនាចំនួន ១៧គ្រឿង និងថ្នាក់ធិបឌិន្ទចំនួន ១៧គ្រឿង ថ្នាក់សេនាចំនួន ១៣គ្រឿង និងថ្នាក់អស្សប្បទ្ធិចំនួន ០១គ្រឿង) មេដាយសហមេត្រីថ្នាក់ធិបឌិនចំនួន ០១គ្រឿង មេដាយស្ថាបនាជាតិចំនួន ៦២គ្រឿង (មេដាយមាសចំនួន ៣៧គ្រឿង មេដាយប្រាក់ចំនួន ១៨គ្រឿង និងមេដាយសំរិទ្ធចំនួន ០៧គ្រឿង) ដើម្បីផ្តល់ជូនសប្បុរសជន ដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តតាកែវ បាត់ដំបង កំពត ស្វាយរៀង និងខេត្តព្រៃវែង ដោយចំណាយអស់ថវិកាសរុបចំនួន ១០.០៤៦.៩៤៧ដុល្លារ (ដប់លានសែសិបប្រាំមួយពាន់ប្រាំបួនរយសែសិបប្រាំពីរដុល្លារអាមេរិក) (ដូចក្នុងឧបសម្ព័ន្ធ ៣)។

**៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF**

-បានសហការរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីពានរង្វាន់សេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២លើក

-បានរៀបចំកិច្ចប្រជុំពិនិត្យ កែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-បានរៀបចំកិច្ចប្រជុំត្រៀមចុះគាំទ្រ តាមដាន និងវាយតម្លៃការអនុវត្តសេវាសង្គមនៅរដ្ឋបាលខេត្តគោលដៅ

-បានចុះគាំទ្រ តាមដាន និងវាយតម្លៃការអនុវត្តសេវាសង្គមនៅរដ្ឋបាលខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តក្រចេះ និងខេត្តរតនគិរី

-បានចុះគាំទ្រវគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍សម្រាប់ឃុំ សង្កាត់ សរុបចំនួន៥វគ្គ នៅខេត្តកំពង់ស្ពឺចំនួន១វគ្គ ខេត្តកំពង់ធំចំនួន២វគ្គ និងខេត្តកំពង់ឆ្នាំងចំនួន២វគ្គ។

### ៧.៤.២-គម្រោងសាងសង់អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០ ការវិវឌ្ឍនៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាលស្រុក និងឃុំ សង្កាត់ គិតជារួមបានប្រមាណ៤៧% ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចាត់មន្ត្រីៈ

-តាមដានការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគារសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ដំណាក់កាលទី១ និងទី២ទន្ទឹមនេះក្រុមការងារគម្រោងក៏បានរៀបចំកិច្ចសន្យាសាងសង់សម្រាប់កញ្ចប់លទ្ធកម្មទី១១ នៃដំណាក់កាលទី៣។

## ៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់

### ៧.៥.១-គម្រោងមូលនិធិក្រុង ស្រុក

សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៩ មានចំនួន **៥១៦គម្រោង** ដែលក្នុងនោះៈ គម្រោងមិនទាន់សិក្សាចំនួន **២៧គម្រោង** (ស្មើនឹង៥,២៣%) គម្រោងកំពុងដំណើរការសិក្សាចំនួន **៥៦គម្រោង** (ស្មើនឹង ១០,៨៥%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន ៤៣៣គម្រោង(ស្មើនឹង៨៣,៩២%)។សម្រាប់គម្រោងក្រុង ស្រុក ឆ្នាំ២០១៩នេះ បានដេញថ្លៃរួចចំនួន ៣៩១គម្រោង(ស្មើនឹង៩០,៣០%) នៃគម្រោងដែលបានបញ្ចប់ការសិក្សា។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៩ មានចំនួន **៣៤២កិច្ចសន្យា** ក្នុងនោះរួមមានៈ បញ្ចប់ការសាងសង់១០០% ចំនួន **២២២កិច្ចសន្យា** (ស្មើនឹង ៦៤.៩១%) អនុវត្តបានលើស៥០% ចំនួន៦៣កិច្ចសន្យា(ស្មើនឹង ១៨,៤២%) អនុវត្តបានតិចជាង៥០%ចំនួន **២៣កិច្ចសន្យា**(ស្មើនឹង ៦,៧៣%) និងមិនទាន់បានអនុវត្តចំនួន ៣៤កិច្ចសន្យា(ស្មើនឹង ៩,៩៤%)។ ជាមួយគ្នានេះដែរ សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៨ មានចំនួន **៤៨៥គម្រោង** ដែលក្នុងនោះៈ គម្រោងមិនទាន់សិក្សាចំនួន **២៤គម្រោង** (ស្មើនឹង ៤,៩៥%)និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៤៦១គម្រោង**(ស្មើនឹង ៩៥,០៥%) ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាមានចំនួន **៣៧៩គម្រោង**(ស្មើនឹង ៨២,២១%)បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៨ មានចំនួន **៣៧៣កិច្ចសន្យា** ក្នុងនោះរួមមានៈ បានបញ្ចប់ការសាងសង់ ១០០% ចំនួន **៣៧១កិច្ចសន្យា** (ស្មើនឹង-៩៩,៤៦%) និងការអនុវត្តលើសពី៥០% ចំនួន០២កិច្ចសន្យា( ស្មើនឹង ០,៥៤%)។

### ៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់

សំណើគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩ មានចំនួន **១.៨០៤គម្រោង**(ក្នុងនោះ កំពុងសិក្សាចំនួន២៩គម្រោង (ស្មើនឹង១,៦១%) និងបានបញ្ចប់ការសិក្សាចំនួន **១.៧៧៥គម្រោង**(ស្មើនឹង ៩៦,៦៨%) ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **១.៧២៨គម្រោង** ស្មើនឹង ៩៧,៣៥% បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩ សរុបចំនួន **១.៧០០កិច្ចសន្យា** ក្នុងនោះ រួមមានៈ ការអនុវត្តបានលើសពី៥០%ចំនួន **២៧៥កិច្ចសន្យា**(ស្មើនឹង១៦,៨១%) ការអនុវត្តបានតិចជាង ៥០% ចំនួន **១៦៧កិច្ចសន្យា**(ស្មើនឹង ៩,៨២%) បញ្ចប់ការសាងសង់១០០% ចំនួន**៩២៣កិច្ចសន្យា**(ស្មើនឹង៥៤,២៩%) និងមិនទាន់បានអនុវត្តចំនួន **៣៣៥កិច្ចសន្យា**(ស្មើនឹង ១៩,៧១%)។

ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨ មានចំនួន **១.៧៤៨គម្រោង**(ក្នុងនោះ កំពុងសិក្សាចំនួន ០១គម្រោង (ស្មើនឹង០,០៦%) និងបានបញ្ចប់ការសិក្សាចំនួន **១៧៤៧គម្រោង** (ស្មើនឹង ៩៩,៩៤%) ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **១៧៣៨គម្រោង** (ស្មើនឹង ៩៩,៤៨%) បានដេញថ្លៃរួចរាល់ ។ ទន្ទឹមនោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨សរុបចំនួន **១.៧៣៦កិច្ចសន្យា** ក្នុងនោះរួមមានៈ ការអនុវត្តបានលើសពី៥០%ចំនួន ៣៤កិច្ចសន្យា(ស្មើនឹង១,៩៦%) ការអនុវត្តបានតិចជាង៥០%ចំនួន **១២កិច្ចសន្យា**(ស្មើនឹង០,៦៩%) បញ្ចប់ការសាងសង់១០០%ចំនួន **១.៦៨០កិច្ចសន្យា**(ស្មើនឹង៩៦,៧៧%)មិនទាន់បានអនុវត្តចំនួន ០៨កិច្ចសន្យា (ស្មើនឹង ០,៤៦%) និងបោះបង់ចោលចំនួន ០២កិច្ចសន្យា(ស្មើនឹង០,១២%)។

**៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន**

**៧.៦.១-ការផ្ទេរមុខងារ និងធនធាន**

-បានជួយសម្របសម្រួលដល់រដ្ឋបាលរាជធានីភ្នំពេញក្នុងការរៀបចំ និងដាក់ចេញដីកាស្តីពីការធ្វើប្រតិភូកម្មមុខងារពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌនីមួយៗនៃរាជធានីភ្នំពេញ

-បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារធនាគារពិភពលោក ដើម្បីបន្តការពិភាក្សាលើដំណើរការនៃការរៀបចំគម្រោងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅរដ្ឋបាលក្រុង ស្រុកគោលដៅអាទិភាពមួយចំនួន

-បានចុះសិក្សា និងប្រមូលព័ត៌មានអំពីស្ថានភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការគ្រប់គ្រងទីលានចាក់សំរាមនៅក្រុង ស្រុកគោលដៅមួយចំនួននៃខេត្តបាត់ដំបង និងខេត្តកំពង់ស្ពឺ។

**៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ**

**ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ**

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន **៥៦.២៤២សេវា** ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ឃើញថាវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្តល់សេវាបានច្រើនជាងគេគឺចំនួន ២០.៤៧៩សេវា(ស្មើនឹង ៣៦,៤១%)បន្ទាប់មកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១២.៩៤៤សេវា (ស្មើនឹង២៣,០១%) (**ដូចក្នុងឧបសម្ព័ន្ធ៤**)។ជាមួយគ្នានេះដែរអង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន ៦.១៧៣.៩២៩.៦២៩រៀល (ស្មើនឹង១.៥៤៣.៤៨២,៤០៧ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺ ៤.៥៨៨.៣៤៥.៦២៩រៀល (ស្មើនឹង៧៤,៣២%) បន្ទាប់មកវិស័យការងាររដ្ឋបាលទទួលបានចំណូលចំនួន ៣១៤.៤៥៨.៩០០រៀល(ស្មើនឹង ៥,០៩%) រីឯវិស័យវប្បធម៌ និងវិចិត្រសិល្បៈទទួលបានចំណូលតិចជាងគេគឺចំនួន ២០.០០០រៀល (ស្មើនឹង ០.០០៣%) (**ដូចក្នុងឧបសម្ព័ន្ធ៥**)។

**ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ**

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅបានផ្តល់សេវារដ្ឋបាលសរុបចំនួន ១៤៩.៣៤៩សេវា បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យនីត្យានុកូលកម្មបានផ្តល់សេវាបានច្រើនជាងគេគឺ ៨៤.៣៦៥សេវា (ស្មើនឹង៥៦,៤៩%) បន្ទាប់មកវិស័យសាធារណការ និងដឹកជញ្ជូនចំនួន ៤៧.៩៤៤សេវា (ស្មើនឹង ៣២,១០%) រីឯវិស័យរ៉ែ និងថាមពលបានផ្តល់សេវាតិចជាងគេគឺចំនួន ០២សេវា (ស្មើនឹង ០,០០១%) (**ដូចក្នុងឧបសម្ព័ន្ធ៦**)។ រយៈពេលដូចគ្នានេះដែរការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅ ទទួលបានប្រាក់ចំណូលសរុបចំនួន **១.៣៥៩.៧៦៨.៦១០រៀល** (ស្មើនឹង ៣៣៩.៩៤២,១៥២ដុល្លារអាមេរិក) បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង១៤ ឃើញថាវិស័យសុរិយោដីមានចំណូលខ្ពស់ជាងគេគឺចំនួន ៦១០.០២០.០០០រៀល (ស្មើនឹង ៤៤,៨៦%)បន្ទាប់មកវិស័យសំណង់ទទួលបានចំណូលចំនួន ២៥១.៦៥៧.៦០០រៀល (ស្មើនឹង១៨,៥១%) រីឯវិស័យរ៉ែ និងថាមពល បានផ្តល់ចំណូលតិចជាងគេគឺចំនួន១០០.០០០រៀល(ស្មើនឹង ០,០០១%)(**ដូចក្នុងឧបសម្ព័ន្ធ៧**)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួនដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេស នៃការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញនីមួយៗសម្រាប់ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ ៣២គោលដៅថ្មី

-បានគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយទាំង៣២គោលដៅថ្មី ក្នុងឆ្នាំ២០១៩ អំពីការរៀបចំការិយាល័យ និងការជ្រើសរើសមន្ត្រីជួរក្រោយនៅក្នុងការិយាល័យច្រកចេញចូលតែមួយ

-បានដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធទូទាត់ថ្លៃសេវារបស់ក្រុមហ៊ុនលីហ្គូ ផេប្រ៉ូ នៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌចំនួន០៤គោលដៅ។

**៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបានទទួលបណ្តឹង សំណូមពរ ការរិះគន់ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៧១ករណី** ក្នុងនោះ បណ្តឹងក្នុងសមត្ថកិច្ចចំនួន **២៥ករណី** (បញ្ចប់ការដោះស្រាយ ១៥ករណី កំពុងដោះស្រាយ ១០ករណី) បណ្តឹងក្រៅសមត្ថកិច្ច ចំនួន**១៩ករណី** សំណូមពរចំនួន **០៥ករណី** និងការសាកសួរព័ត៌មានផ្សេងៗចំនួន **២២ករណី**។ ជាមួយគ្នានេះដែរ **អគ្គនាយកដ្ឋានរដ្ឋបាល** ក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដូចខាងក្រោម៖

-បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តកំពត និងខេត្តកោះកុង

-បានគាំទ្រប្រធានការិយាល័យប្រជាពលរដ្ឋខេត្តបាត់ដំបងអំពីការត្រៀមធ្វើបទបង្ហាញចែករំលែកបទពិសោធន៍នៅក្នុងសិក្ខាសាលាប្រចាំឆ្នាំ២០១៩

-បានតាមដាន និងគាំទ្រលើការដាក់ឲ្យដំណើរការរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ពាក់ព័ន្ធនឹងការតែងតាំងបុគ្គលិកសម្រាប់បំពេញការងារ ការបំពាក់សម្ភារប្រើប្រាស់ ការអនុវត្តតួនាទី ភារកិច្ច និងបញ្ហាប្រឈមនានារបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ

-បានគាំទ្រការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អំពីប្រព័ន្ធកត់ត្រាបណ្តឹង និងការរៀបចំរបាយការណ៍

-បានដាក់ចេញប្រកាសទទួលស្គាល់អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តកំពង់ធំ។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង សំណូមពរ ការរិះគន់ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៨៤៤ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ច **១៧ករណី** (បញ្ចប់ការដោះស្រាយ **១៣ករណី** កំពុងដោះស្រាយ **០៤ករណី**)និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន **១៦ករណី** ការសរសើរចំនួន **២១ករណី** សំណូមពរចំនួន **៨០ករណី** ការសាកសួរព័ត៌មានផ្សេងៗចំនួន **៧១០ករណី**។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដូចខាងក្រោម៖

-បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ នីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌគោលដៅថ្មីចំនួន៣២គោលដៅឆ្នាំ២០១៩

-បានដាក់ចេញប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋស្រុក៧គោលដៅរួមមាន៖ ស្រុកកំពង់ត្រាច ស្រុកសាលាក្រៅ ស្រុកកោះធំ ស្រុកកំពង់ត្របែក ស្រុកមេមត់ ស្រុកបន្ទាយស្រី និងស្រុកមុខកំពូល

-បានរៀបចំសំណើសុំប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុងតាខ្មៅថ្មីជំនួសប្រធានការិយាល័យប្រជាពលរដ្ឋចាស់ដែលបានទទួលមរណៈភាព។

**៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន អង្គភាពនានា និងរដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម៖

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ៖ ករណីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្នើសុំផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពសម្រាប់ឆ្នាំ២០១៩ នៃការអនុវត្តផែនការសកម្មភាពគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥។

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ករណីសំណើសុំរៀបចំវគ្គបណ្តុះបណ្តាលអំពីច្បាប់ស្តីពីសំណង់ដល់អាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធចាំបាច់នៅថ្នាក់ក្រោមជាតិ។

-ក្រសួងសុខាភិបាល ករណីសំណើសុំអញ្ជើញអភិបាលរាជធានី ខេត្ត ចូលរួមក្នុងពិធីសន្និបាតបូកសរុបការងារសុខាភិបាលឆ្នាំ២០១៩ លើកទី៤១។

-អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ករណីស្នើសុំអនុញ្ញាតបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី"ការិយាល័យព័ត៌មានឈ្លាសវៃ និងអភិបាលកិច្ចល្អក្នុងវិស័យព័ត៌មាន"

-រដ្ឋបាលខេត្តប៉ៃលិន កណ្តាល បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តបន្ទាយមានជ័យ ករណីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាស្នើសុំសម្របសម្រួលដល់ការចុះបំពេញបេសកកម្មរបស់គណៈកម្មការទី២ ទី៥ ទី៧ និងទី១០នៃព្រឹទ្ធសភា។

-រដ្ឋបាលខេត្តកំពង់ចាម៖ ករណីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្នើសុំរៀបចំវេទិកាថ្នាក់ស្រុករបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នៅស្រុកចំការលើ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

-រដ្ឋបាលខេត្តកំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម បាត់ដំបង ក្រចេះ ស្ទឹងត្រែង រតនគិរី និងរដ្ឋបាលខេត្តមណ្ឌលគិរី៖ ករណីអគ្គលេខាធិការដ្ឋានរដ្ឋសភាស្នើសុំសម្របសម្រួលដល់ការចុះបំពេញបេសកកម្មរបស់គណៈកម្មការទី១ ទី២ ទី៣ ទី៧ និងទី៨ នៃរដ្ឋសភា។

-វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាករណីស្នើសុំអញ្ជើញអភិបាលរាជធានី ខេត្ត ចូលរួមក្នុងសន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០២០ ក្រោមប្រធានបទ "កិច្ចសហការក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីក្រុងឆ្លាតនាពេលអនាគត"។

-បានរៀបចំលិខិតជម្រាបជូនប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានរាជធានី ខេត្ត ដើម្បីអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត។

### ៩.ការងារតាមវិស័យផ្សេងៗ

#### ៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមាន ច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។

ចាប់តាំងពីដាក់ឱ្យដំណើរការប្រើប្រាស់ជាផ្លូវការនូវប័ណ្ណព្រំដែនកម្ពុជា-ថៃនិងប័ណ្ណព្រំដែនកម្ពុជា-ឡាវ រហូតមកដល់បច្ចុប្បន្ន អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើការតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងសម្ភារៈជូនទៅរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ និងប្រទេសឡាវជាប្រចាំ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋឱ្យប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែង អគ្គនាយកដ្ឋានរដ្ឋបាលក៏បានធ្វើលិខិតជម្រាបជូនរដ្ឋបាលខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តកោះកុងករណីស្តីពីការពង្រឹងបន្ថែមនូវការងារផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ។

គិតចាប់ពីថ្ងៃទី១៩ខែមករា ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ អគ្គនាយកដ្ឋានរដ្ឋបាលបានផ្តល់ប័ណ្ណព្រំដែនជូនរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃសរុបចំនួន៩.០០០ក្បាលក្នុងនោះរួមមាន៖ ខេត្តបន្ទាយមានជ័យចំនួន៥.០០០ក្បាល ខេត្តប៉ៃលិនចំនួន៣.០០០ក្បាល និងខេត្តកោះកុង ចំនួន ១.០០០ក្បាល។ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការសរុបចំនួន ៩.២៨៨ក្បាល ក្នុងនោះរួមមាន៖ (ខេត្តបាត់ដំបង-

ចំនួន ៣.៥៩៩ក្បាល ខេត្តបន្ទាយមានជ័យចំនួន ២.២៤៨ក្បាល ខេត្តឧត្តរមានជ័យ ចំនួន ១.៦៨៥ក្បាល ខេត្តប៉ៃលិន ចំនួន ១.៣៨៦ក្បាល និងខេត្តកោះកុងចំនួន ៣៧០ក្បាល) ។ ការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋសម្រាប់បណ្តាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ចំនួន ០១ក្បាល(ដូចក្នុងឧបសម្ព័ន្ធ៨)។

**៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃដើម្បីស្នើសុំគោលការណ៍ដឹកនាំ ដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល និងបានអនុញ្ញាតជាគោលការណ៍ឱ្យរដ្ឋបាលរាជធានី ខេត្ត ចុះហត្ថលេខាលើអនុស្សរណៈ(MOU) ផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា និងកិច្ចសហប្រតិបត្តិការដូចខាងក្រោម៖

-ក្រសួងមហាផ្ទៃករណីរាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមជាគោលការណ៍អនុញ្ញាត៖

- ដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧ នៅទីក្រុងប៉ាតាយ៉ាខេត្តឈុនបុរី នៃព្រះរាជាណាចក្រថៃ។
- រដ្ឋបាលខេត្តកោះកុង ស្នើសុំចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីការបង្កើតចំណងមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងខេត្តកោះកុង និងខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តសៀមរាប ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យក្រុមហ៊ុន NIPPON KOEI របស់ប្រទេសជប៉ុនដើម្បីធ្វើបទបង្ហាញអំពីគម្រោងសេវាកម្មចល័តថ្មី សម្រាប់បម្រើឱ្យទេចរណ៍ឆ្លាតវៃក្នុងក្រុងសៀមរាបនៃ ខេត្តសៀមរាប ។

-រដ្ឋបាលខេត្តកំពត ករណីភាគីវៀតណាម ស្នើសុំជួសជុលកែលម្អផ្លូវសេងខាងជាប់បង្គោលព្រំដែនលេខ ៣១៣ ស្ថិតនៅក្នុងតំបន់ច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក (កំពត)-ហាទៀង (គៀនយ៉ាង)។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីស្នើសុំគោលការណ៍អនុញ្ញាតដឹកនាំគណៈប្រតិភូទៅបំពេញទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រងសំណល់រឹង នៅចក្រភពអង់គ្លេស។

-រដ្ឋបាលខេត្តព្រះវិហារ ករណីឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ស្នើសុំជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ។

-រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាលខេត្តសៀមរាប ចំពោះករណីសុំផ្តល់របាយការណ៍ពាក់ព័ន្ធនឹងគម្រោងទីក្រុងឆ្លាតរបស់រាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ករណីទីក្រុងសេជុង(Sejong City) នៃសាធារណរដ្ឋកូរ៉េមានបំណងបង្កើតចំណងសម្ព័ន្ធមេត្រីភាពជាមួយរាជធានី ខេត្តណាមួយ នៃព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ករណីសុំផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-សហរដ្ឋអាមេរិក។

**៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច លើសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន ៨០គម្រោងរបស់រដ្ឋបាលរាជធានី ខេត្ត ចំនួន០៦រួមមាន៖ រាជធានីភ្នំពេញ(៤២គម្រោង) ខេត្តបន្ទាយមានជ័យ (១គម្រោង) ខេត្តឧត្តរមានជ័យ (៥គម្រោង) ខេត្តសៀមរាប (២២គម្រោង) ខេត្តព្រះវិហារ(៦គម្រោង) និងខេត្តព្រះសីហនុ (៤គម្រោង) មានទឹកប្រាក់សរុបចំនួន ២២៦.២៨១.៩៤៨.៩៦០រៀល (ពីររយម្ភៃប្រាំមួយប៊ីលានពីររយប៉ែតសិបមួយលានប្រាំបួនរយប៉ែតសិបប្រាំបីពាន់ប្រាំបួនរយហុកសិបរៀលគត់) និងគម្រោងអភិវឌ្ឍ ឆ្នាំ២០២០ ចំនួន៥គម្រោង របស់រដ្ឋបាលខេត្ត ចំនួន២រួមមាន៖ ខេត្តស្វាយរៀង(៤គម្រោង) និងខេត្តស្ទឹងត្រែង(១គម្រោង) មានទឹកប្រាក់សរុបចំនួន ១០.០៨៦.០៣០.០០០រៀល (ដប់ប៊ីលានប៉ែតសិបប្រាំមួយលានសាមសិបពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៨)។ ទន្ទឹមនោះដែរក្រសួងមហាផ្ទៃក៏បានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០១៩ចំនួន៣០គម្រោង របស់រដ្ឋបាលរាជធានីខេត្តចំនួនខេត្តតាកែវ(៣គម្រោង) មានទឹកប្រាក់សរុបចំនួន ៦៥.៣៥៣.៧៤៦.០០០ រៀល (ហុកសិបប្រាំប៊ីលានបីរយហាសិបបីលានប្រាំពីររយសែសិបប្រាំមួយពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៩)។

ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបជូនទៅក្រសួង ស្ថាប័ននានា អង្គភាពចំណុះ និងរដ្ឋបាលខេត្តមួយចំនួនដូចខាងក្រោម៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីរដ្ឋបាលខេត្តស្ទឹងត្រែង ស្នើសុំគោលការណ៍ដោះដូរដីរបស់រដ្ឋបាលខេត្តស្ទឹងត្រែងទំហំ ៥៩,៤៤ហិកតា ស្ថិតនៅភូមិគីឡូ៨ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជាមួយដីឯកជនចំនួន ២០០ឡូតិ៍ ដែលក្នុងមួយឡូតិ៍ទំហំ ៥ម៉ែត្រ x ២០ម៉ែត្រ ស្ថិតនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជូនប្រជាពលរដ្ឋចំនួន ១៣៩គ្រួសារ។

-អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ករណីសំណើសុំគោលការណ៍កាត់ដីទំហំ ៨១.៥២២ម៉ែត្រការ៉េ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលក្រុងបាវិត ខេត្តស្វាយរៀង។

-រដ្ឋបាលខេត្តក្រចេះ៖ ករណីឈ្មោះ ឆោម គឹម ស្នើសុំទៅ សម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីសុំទិញដីទំហំ ៧៨.៤០០ម៉ែត្រការ៉េ ស្ថិតនៅភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ និងធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដើម្បីធ្វើការអភិវឌ្ឍន៍ជាបុរី ។

-រដ្ឋបាលខេត្តកណ្តាល ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យ៖

• ក្រុមហ៊ុន ដេឌី ឌីវេឡុបមេន ឯ.ក បានសាងសង់ច្រាំងទន្លេមេគង្គប្រវែង១៥គីឡូម៉ែត្រ ស្ថិតក្នុងភូមិសាស្ត្រ ឃុំឫស្សីជ្រោយ ឃុំព្រែកដំបង ឃុំកោះកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល និងឃុំស្ដៅ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម។

• ក្រុមហ៊ុនអាណាចក្រឌីវេឡុបមេនគ្រុប ស្នើសុំកំណត់រយៈពេលជួលដី ថ្លៃឈ្នួល និងលក្ខខណ្ឌអនុគ្រោះលើសំណើសុំវិនិយោគលើទីតាំងដីទំហំ ២២៣ហិកតា ២.៧៥១ម៉ែត្រការ៉េ ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេស និង តំបន់ពាណិជ្ជកម្មពហុបំណុងរបស់ក្រុមហ៊ុន អាណាចក្រឌីវេឡុបមេនគ្រុប ដែលមានទីតាំងស្ថិតនៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

• (១).ចុះបញ្ជីដីទំហំ ៧០ហិកតា ស្ថិតនៅភូមិអរិយក្សត្រ និងភូមិខ្សាច់ ស្រុកល្វាឯម ខេត្តកណ្តាល ជូនរដ្ឋបាលខេត្តកណ្តាល និង(២).ចុះបញ្ជីដីចំនួន ០២ទីតាំង ដែលទីតាំងទី១ ទំហំ ៦៣.៣២៥ម៉ែត្រការ៉េ និងទីតាំងទី២ ទំហំ ១១១.៧៤៧ម៉ែត្រការ៉េ ស្ថិតនៅភូមិអរិយក្សត្រ និងភូមិខ្សាច់ ស្រុកល្វាឯម ខេត្ត កណ្តាល ជូនក្រុមហ៊ុនយុន សៀ អ៊ីមផតអិចផត ជាកម្មសិទ្ធិឯកជន។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ៖ ករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាត់មន្ត្រីជំនាញចូលរួមក្នុងគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ និងសិក្សាវាយតម្លៃការដោះដូរទីតាំងដីមណ្ឌលសុខភាពប៉ោយប៉ែត១ ជាថ្នូរនឹងការអភិវឌ្ឍទីតាំងថ្មីជូនមណ្ឌលសុខភាពប៉ោយប៉ែត១ ស្ថិតនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃសរុប ចំនួន ៥.៦១១(ក្នុងនោះសមាគមចំនួន ២.២៧៨ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៣៣៣) និងសហគមន៍ជនជាតិដើមភាគតិចចំនួន១៤១ (**ដូចក្នុងឧបសម្ព័ន្ធ១១**)។ ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២១ (ក្នុងនោះសមាគម១៧ អង្គការមិនមែនរដ្ឋាភិបាល៤ ព្រមទាំងបានសម្រេចលុបឈ្មោះចេញពីបញ្ជីអង្គការមិនមែនរដ្ឋាភិបាលតាមការស្នើសុំសរុបចំនួន៤(**ដូចក្នុងឧបសម្ព័ន្ធ១១**)។ ជាមួយគ្នានេះផងដែរ ក៏បានបញ្ចូលទិន្នន័យស្តេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៣១ច្បាប់ ក្នុងនោះសមាគមចំនួន ២១ច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០ច្បាប់។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានាដូចជា ការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃ របនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃ ក៏បានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤ ។

**៩.៤.២-ការងារគណបក្សនយោបាយ**

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប ៤៦គណបក្ស ក្នុងនោះគណបក្សដែលបានចុះបញ្ជីមានចំនួន ៤៣គណបក្ស និងគណបក្សដែលបានបង្កើតមានចំនួន ០៣គណបក្ស (**ដូចក្នុងឧបសម្ព័ន្ធ១១**)។ ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានពិនិត្យ និងបូកសរុបរបាយការណ៍ស្តីពីសកម្មភាពសំខាន់ៗ និងរបាយការណ៍ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៩ របស់គណបក្សនយោបាយដាក់ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីស្នើសុំគោលការណ៍ពិនិត្យ និងសម្រេច។

**II-<u>បញ្ហាប្រឈម និងសំណូមពរ</u>**

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-ការបញ្ជូនឯកសារពីក្រសួងមហាផ្ទៃទៅកាន់រដ្ឋបាលរាជធានី ខេត្ត និងការបញ្ជូនឯកសារពីរដ្ឋបាលរាជធានី ខេត្តមកក្រសួងមហាផ្ទៃនៅតែមានភាពយឺតយ៉ាវ

-ការផ្គត់ផ្គង់សម្ភារៈការិយាល័យដូចជាក្រដាស ទឹកថ្នាំ ម៉ាស៊ីនថតចម្លងដើម្បីឆ្លើយតបសំណូមពរការងារមិនទាន់បានគ្រប់គ្រាន់ហើយការបើកសម្ភារៈពុំសូវមានគុណភាព

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្ត មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុនហើយបន្ទាប់ពីបញ្ចប់បេសកកម្មការបើកផ្តល់មានភាពយឺតយ៉ាវ។

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ **អគ្គនាយកដ្ឋានរដ្ឋបាល** សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាដើម្បីធានាឆ្លើយតបសំណូមពរការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្តិចបន្ទាប់ពីចុះបំពេញបេសកកម្ម។

**III-<u>ទិសដៅការងារបន្ត</u>**

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែមីនាឆ្នាំ២០២០ ដូចខាងក្រោម៖

**១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត និងការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី«កិច្ចការរដ្ឋបាល»សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន របស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងក្របខ័ណ្ឌតាមដានត្រួតពិនិត្យវាយតម្លៃលើផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាព មន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅស្តីពីអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

-សេចក្តីព្រាងស្តង់ដាអតិបរមាសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ប្រ.ក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៦ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពី ការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-បន្តរៀបចំបែបបទប្រឡងជ្រើសរើស សិស្ស និស្សិតឱ្យចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការមហាផ្ទៃ ក្នុងផែនការក្របខណ្ឌឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០២០

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មី និងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកបត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-រៀបចំពិនិត្យផ្ទៀងផ្ទាត់សលាកបត្រមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ដែលដល់អាយុត្រូវចូលនិវត្តន៍ឆ្នាំ២០២០

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីស៊ុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ធានារ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តរៀបចំផ្លាស់ប្តូរកន្លែងធ្វើការរៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល ០៣ខែ សម្រាប់មន្ត្រីរាជការស៊ីវិល និងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារ និងរៀបចំតារាងបៀវត្សកែតម្រូវឱ្យត្រូវតាមរចនាសម្ព័ន្ធនៃអង្គភាពនីមួយៗ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាព និងតែងតាំងទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ និងទីប្រឹក្សា ជំនួយការសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បន្តរៀបចំការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ

-បន្តធ្វើការតែងតាំងទីប្រឹក្សា ជំនួយការ និងរៀបចំស្នើសុំប្រាក់បៀវត្សទីប្រឹក្សា ជំនួយការ

-បន្តរៀបចំក្រុមការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-បន្តរៀបចំការផ្អាកការងារ ដោយផ្អាកបៀវត្ស។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការចុះចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការ នៅតាមសាលារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ(និង០៨ឆ្នាំ)របស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយលើការងារប្រកាសទ្រព្យសម្បត្តិ និង បំណុលសម្រាប់ឆ្នាំ២០២០។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-សិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រប់ការិយាល័យដែលពាក់ព័ន្ធចំណុះនាយកដ្ឋានបុគ្គលិក

-បន្តសហការជាមួយក្រុមហ៊ុនក្នុងការរៀបចំប្រព័ន្ធឲ្យមានភាពល្អប្រសើរជាងមុន

-បន្តធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាបន្តបន្ទាប់

-បន្តសហការជាមួយមន្ត្រីបង្គោល នៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលប្រវត្តិរូបមន្ត្រីកម្មសិក្សាក្របខ័ណ្ឌថ្មីឆ្នាំ២០២០ និងមន្ត្រីដែលទើបផ្ទេរចូលថ្មី រួមទាំងឯកសារមន្ត្រីរាជការដែលមានការប្រែប្រួលស្ថានភាពជាបន្ត បន្ទាប់

-ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជាការផ្លាស់ប្តូរទីកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។ ទៅក្នុងប្រព័ន្ធ។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅជាមន្ត្រីនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-បន្តរៀបចំឯកសារបណ្តុះបណ្តាលសម្រាប់ស្មៀនឃុំ សង្កាត់

-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

-រៀបចំកិច្ចការចាំបាច់នានាសម្រាប់ដាក់ឲ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)

-សិក្សាស្រាវជ្រាវ និងចងក្រងឯកសារអភិបាលកិច្ចមូលដ្ឋាន។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

-បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល

-បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

**៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៤.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច និងបន្តអនុវត្តលើកិច្ចការមួយចំនួនដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីឈ្មោះ ខូវ ម៉េង និងឈ្មោះ កែ គុយហ៊ាង ស្នើសុំអន្តរាគមន៍ជួយដោះស្រាយចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលមានទីតាំងផ្ទះលេខ ១០៧អា និងផ្ទះលេខ ១០៨អា ផ្លូវ៧០ ភូមិ១ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណី៖

- ឈ្មោះ អ៊ូ ប៊ុនណារិទ្ធ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តបន្ទាយមានជ័យ ដើម្បីធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុមួយកន្លែង ស្ថិតនៅភូមិអណ្តូងថ្មមាស សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពក្រុមជនអនាធិបតេយ្យចូលរំលោភបំពានកាន់កាប់ដីរដ្ឋ និងដីមានប័ណ្ណកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ ដែលមានទីតាំងស្ថិតនៅចំណុចអូរកំបុត ចំណុចអាងកន្សែង ភូមិទ័ពសៀម និងចំណុចសំបុកចាប ភូមិបឹងស្នោ ឃុំស្លក្រាម ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។
- គណបក្សកសិករ ធ្វើសេចក្តីរាយការណ៍អំពីភាពអសកម្មរបស់លោក គាត ហ៊ុល អភិបាលក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជុំវិញការមិនជួយដោះស្រាយការងារជូនប្រជាពលរដ្ឋ និងមិនអនុវត្តលិខិតអន្តរាគមន៍របស់ក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងវិវាទដីធ្លីរបស់ឈ្មោះ នួន ស្រី ដែលមានដីកម្មសិទ្ធិទំហំ ២០០ម៉ែត្រការ៉េ ស្ថិតនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។
- ឈ្មោះ ប៉ូច ប៉េង ស្នើសុំជួយអន្តរាគមន៍ដោះស្រាយរកយុត្តិធម៌ ករណីទំនាស់ដីធ្លីទំហំ ៣៥ហិកតា មានទីតាំងនៅខាងជើងភូមិព្រៃសង្ហារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងសុំបដិសេធលិខិតលេខ ១៧១/១៩ របក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ។

•ស្នើសុំដីសម្បទានសង្គមកិច្ចទំហំ ១១ហិកតា សម្រាប់ចែកជូនប្រជាពលរដ្ឋក្រីក្រ និងខ្វះទីជំរកចំនួន ២៨៦គ្រួសារ ស្ថិតនៅចំណុចចាន់គិរី សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តតាកែវ ករណីឈ្មោះ ឥន្ទ គា, ឡុត ស្រីពៅ, គាំង ថា, តាំង សៀន, សុំ សុខលី, អៀម នាង, អ៊ូ ប៊ុណ្ណា, ហាក់ ហេង, ថាវ សុគន្ធ, អួន ថា, សែត ខុន និងដួង សុខា ស្នើសុំចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋចំនួន ១២គ្រួសារ ស្ថិតនៅភូមិ២ សង្កាត់កោះក្ដាង ក្រុងដូនកែវ ខេត្តតាកែវ។

-រដ្ឋបាលខេត្តកំពង់ចាម ករណីស្នើសុំការអនុញ្ញាតសាងសង់អគារសភាពាណិជ្ជកម្មខេត្តកំពង់ចាម និងខេត្តមណ្ឌលគិរី ក្នុងបរិវេណសាលាខេត្តកំពង់ចាម ទំហំ ១០ម x ២០ម។

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីឈ្មោះ ហេង វណ្ណៈ ស្នើសុំប្ដឹងឈ្មោះ ម៉ី ខេត ជាមេឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងបក្ខពួកលើករណីប្រើអំណាច ឃុបឃិតគ្នាលក់ដីរបស់គាត់ឱ្យអ្នកផ្សេងស្ថិតនៅភូមិរលួស ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីសំណើសុំអនុញ្ញាតដើម្បីប្រើប្រាស់ទង់និមិត្តសញ្ញាខេត្តកំពង់ស្ពឺ ជាផ្លូវការក្នុងកម្មវិធីបុណ្យជាតិ-អន្តរជាតិផ្សេងៗរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តកែប ករណីធ្វើសេចក្ដីរាយការណ៍អំពីកិច្ចការជួយសង្គ្រោះជនរងគ្រោះក្នុងឧបទ្ទវហេតុលំបាក់អគារ ៦ជាន់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប។

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

•ឈ្មោះ ហុក ឡេង ស្នើសុំចាត់វិធានការលើជនខិលខូចឃុបឃិតគ្នាធ្វើប្លង់ និងរំលោភយកដីរបស់គាត់ចំនួន ០៤ទីតាំង ស្ថិតនៅសង្កាត់លេខ២ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ឃុំរាម និងឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

•ឈ្មោះ អ៊ឹង សាមី, ទៀប ហ៊ន, ទេព គឿន, សុខ ស៊ីវ៉ុធ, ខឹមជា សាឃឿន, លឹម ឡែន, ច្រឹក យីន, យិន ស្រ៊ន, ឡុញ វណ្ណៈ, ទៀ សមស័ក្តិ និងឈ្មោះ ម៉ៅ ឈុន ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុជួយពន្លឿនលិខិតលេខ ៥១៣/១៨ សជណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តព្រះសីហនុ ស្ដីពីចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ និងអង្កេតដីទំហំ ៣២ហិកតា សម្រាប់ចុះបញ្ជីក្បាលដី និងកសាងប័ណ្ណកម្មសិទ្ធិ ស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

-រដ្ឋបាលខេត្តត្បូងឃ្មុំ ករណីធ្វើសេចក្ដីរាយការណ៍អំពីលទ្ធផលគណៈប្រតិភូអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនចុះពិនិត្យសំណង់ផ្លូវក្រវ៉ាត់ព្រំដែន។

-រដ្ឋបាលខេត្តព្រៃវែង ករណីធ្វើសេចក្ដីរាយការណ៍អំពីការដោះស្រាយវិវាទប្រឡាយទឹក តា ហ៊ុយ ស្ថិតនៅឃុំត្រពាំងតាយ៉ង ឃុំកំពង់ប្រាសាទ និងឃុំឫស្សីស្រុក ស្រុកពាមជរ និងប្រឡាយទឹកចំនួន ០៣ខ្សែទៀត មានប្រឡាយទឹកភូមិឈើទាល ប្រឡាយទឹកភូមិឥដ្ឋ និងប្រឡាយទឹកភូមិពេន។

-បន្តរៀបចំសម្របសម្រួលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តរៀបចំ កែសម្រួលនូវប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹង ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការបង្កើតភូមិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្ដាល ដោយកាត់យកផ្ទៃដីទំហំ ៣៧៦ហិកតា ពីក្រុងតាខ្មៅ ខេត្តកណ្ដាល មកឱ្យក្រោមការគ្រប់គ្រងរបស់ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក និងភូមិចំនួន ០៥ ស្ថិតក្នុងឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តតាកែវ ករណីរដ្ឋបាលឃុំកំពង់រាបឃុំព្រៃល្វា ស្នើសុំបំបែកភូមិ ចំនួន ០៣ ស្ថិតក្នុងឃុំកំពង់រាប និងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

-រដ្ឋបាលខេត្តព្រៃវែង ករណីស្នើសុំបំបែកភូមិចំនួន ០៤ភូមិ ស្ថិតនៅក្នុងឃុំកំពង់ពពិល ចំនួន ០១ភូមិ និងឃុំកញ្ជំ ចំនួន ០៣ភូមិ នៃស្រុកពារាំង ខេត្តព្រៃវែង។

-រដ្ឋបាលខេត្តកំពត ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ។

-រដ្ឋបាលខេត្តសៀមរាប ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តសៀមរាប ជាមួយខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។

**៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ស.ជ.ណ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តបាត់ដំបង ស្វាយរៀង និងខេត្តកំពង់ចាម ។

**៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF**

-បន្តរៀបចំសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តរៀបចំសំណើសុំថវិកាអនុវត្តគម្រោងត្រីមាសទី១ឆ្នាំ២០២០

-បន្តចុះតាមដានការអនុវត្តសកម្មភាពសេវាសង្គមនៅរាជធានី ខេត្តគោលដៅ

-បន្តរៀបចំប្រព័ន្ធទិន្នន័យអនឡាញ (Data Base of SNAs) របស់រដ្ឋបាលរាជធានី ខេត្ត។

**៤.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

-បន្តតាមដាន និងសម្របសម្រួលទាក់ទងនឹងសំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរក្សាការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-រៀបចំកិច្ចសន្យាសាងសង់សម្រាប់កញ្ចប់លទ្ធកម្មទី១.១នៃគម្រោង ក្នុងដំណាក់កាលទី៣

-បន្តចុះពិនិត្យ និងតាមដានដំណើការសាងសង់អគារសាលាស្រុក និងឃុំ សង្កាត់ដំណាក់កាលទី១ និងទី២។

**៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-ចុះតាមដាន ការអនុវត្តថវិកាក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៩ និងការរៀបចំថវិកាក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៩-២០២១ និងឆ្នាំ២០២០-២០២២

-បន្តសិក្សាអំពីក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការអភិវឌ្ឍ និងផែនការថវិការួមទាំងបែបបទនៃការអនុវត្តក្រុង ស្រុក ឃុំ សង្កាត់

-ត្រៀមរៀបចំកិច្ចប្រជុំស្តីពីស្ថានភាពនៃការគាំទ្ររបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ លើកទី៣

-បន្តប្រមូល និងរក្សាទុកទិន្នន័យអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តតាមដានប្រព័ន្ធទិន្នន័យដេញថ្លៃគ្រោងឃុំ សង្កាត់ (BID)

-បន្តជំរុញដំណើរការដេញថ្លៃ និងការចុះកិច្ចសន្យាគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តតាមដានការអភិវឌ្ឍន៍ កម្មវិធីឃុំ សង្កាត់

-បន្តដោះស្រាយពាក្យបណ្តឹងនានា ដែលពាក់ព័ន្ធនឹងក្រុង ស្រុក ឃុំ សង្កាត់។

**៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

-សហការជាមួយធនាគារពិភពលោក ដើម្បីចុះសិក្សា និងប្រមូលព័ត៌មានអំពីស្ថានភាពនៃការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងការគ្រប់គ្រងទីលានចាក់សំរាមនៅក្រុង ស្រុកគោលដៅមួយចំនួនបន្ថែមទៀត

-បន្តសហការជាមួយក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការរៀបចំសេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-បន្តសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងសុខាភិបាលក្នុងការរៀបចំ និងដាក់ចេញប្រកាស អន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរាជធានី ខេត្ត

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

-រៀបចំដាក់ឱ្យដំណើរការកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សេចក្តីណែនាំស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំសង្កាត់

-រៀបចំប្រជុំពិភាក្សាជាមួយក្រុមការងារក្រសួងសាធារណការ អំពីការកែសម្រួលប្រព័ន្ធចុះបញ្ជី និងការផ្ទេរប្រព័ន្ធទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តសហការរៀបចំសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានស្នាដៃល្អក្នុងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ

-គាំទ្រការអនុវត្តតួនាទី ភារកិច្ចការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ផ្សព្វផ្សាយអំពីតួនាទី ភារកិច្ច សមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដល់ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធ

-ពង្រឹងប្រព័ន្ធរបាយការណ៍របស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-កែលម្អប្រព័ន្ធកត់ត្រាបណ្តឹង និងកែសម្រួលប្រព័ន្ធគ្រប់គ្រងទិន្នន័យMIS។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោមៈ

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហូរ និងព្រែកជ្រៃធំ-ព្រែកបិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីត្រៀមលក្ខណសម្បត្តិចូលគុយបាដោះស្រាយបញ្ហាបាក់ច្រាំងទន្លេព្រែកខាងលើឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាពខ្ពស់។

-**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ករណីស្នើសុំរបាយការណ៍ស្តីពីវឌ្ឍនភាពសម្រាប់ឆ្នាំ២០១៩ នៃការអនុវត្តផែនការសកម្មភាពគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥។

-**ក្រសួងបរិស្ថាន** ករណីសុំកិច្ចសហការក្នុងការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ។

-**អគ្គលេខាធិការដ្ឋាន** ករណីស្នើសុំប្រមូលធាតុចូល ដើម្បីរៀបចំសេចក្តីព្រាងវិធានការអនុវត្តលើការរំលោភកាន់កាប់ដីព្រៃឈើ។

-**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** ករណីៈ

- ស្នើសុំការអនុញ្ញាតចុះធ្វើការអង្កេតស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ផ្តោតសំខាន់ទៅលើវិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ និងកំណើនសម្រាប់គ្រប់គ្នានៅប្រទេសកម្ពុជា។

•ស្នើសុំការអនុញ្ញាតចុះធ្វើអង្កេតស្តីពី សេចក្តីជឿជាក់លើការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចផ្តោតសំខាន់ទៅលើការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តក្នុងគ្រួសារ និងទីផ្សារការងារ។

•ស្នើសុំអនុញ្ញាតចុះធ្វើការអង្កេតសម្រាប់ការសិក្សាស្តីពី "ការវិភាគទស្សនយេនឌ័រលើភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងអាហារូបត្ថម្ភ ប្រទេសកម្ពុជា និងប្រទេសឥណ្ឌាភាគខាងត្បូង"។

-មូលនិធិគន្ធបុប្ផា ករណីស្នើសុំធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពី "ក្រមសីលធម៌សម្រាប់បុគ្គលកៀរគរ និងប្រមូល ឬការទទួលវិភាគទានសប្បុរសធម៌នៃមូលនិធិគន្ធបុប្ផាកម្ពុជា"៕

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងចំណុចព្រំដែន**

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី២ របស់ក្រុមការងារចម្រុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម។

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊្វូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញឃឺ នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តពិនិត្យ និងលើកយោបល់ ចំពោះករណីសកម្មភាពបូមខ្សាច់របស់ភាគីវៀតណាម នៅក្បែរតំបន់ព្រំដែនកម្ពុជា-វៀតណាម ស្ថិតនៅភូមិក្អមសំណក្រោម ឃុំក្អមសំណ ស្រុកលើកដែក ខេត្តកណ្តាល។

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ ដល់ដំណើរការណ៍ផ្តល់ប័ណ្ណព្រំដែន ជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវប្រើប្រាស់ ព្រមទាំងបន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅក្រុង ស្រុក និងច្រកនៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជាឱ្យមានភាពប្រសើរ និងប្រសិទ្ធភាពខ្ពស់។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាពនិងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តពិនិត្យលើកយោបល់លើរដ្ឋបាលខេត្តព្រះសីហនុ ករណីៈ

•ស្នើសុំគោលការណ៍អនុញ្ញាតឱ្យលោកវរសេនីយ៍ឯក **Varadan Kumar** បានចូលជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ។

•ស្តីពីនាវាផ្ទាំសមុទ្រឥណ្ឌាចូលចត និងធ្វើទស្សនកិច្ចនៅកំពង់ផែស្វយ័យ ខេត្តព្រះសីហនុ។

-បន្តពិនិត្យលើកយោបល់លើរដ្ឋបាលខេត្តកោះកុង ករណីសំណើគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលខេត្តកោះកុងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតទំនាក់ទំនងមិត្តភាពរវាងខេត្តកោះកុងជាមួយខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

-សំណើរពីរដ្ឋបាលខេត្តសៀមរាប ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលក្រុងសៀមរាប ខេត្តសៀមរាប ចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតសម្ព័ន្ធមេត្រីភាពជាមួយក្រុងស៊ីអាន ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំក្រុមការងារចម្រុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម លើកទី២។

-បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែមកម្ពុជា-វៀតណាមលើកទី១១។

-បន្តសម្របសម្រួលលើករណីស្នើសុំរបាយការណ៍លទ្ធផលកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។

-បន្តពិនិត្យ និងលើកយោបល់ករណីសុំផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-សហរដ្ឋអាមេរិក។

-បន្តពិនិត្យ និងលើកយោបល់ករណីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពីការចាត់វិធានការរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកមានផ្ទុកជំងឺ Coronavrius ឬ Covid-19 នៅកម្ពុជា។

-ត្រៀមរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ នាថ្ងៃទី២២-២៤ ខែមេសា ឆ្នាំ២០២០ នៅទីក្រុងប៉ាតាយ៉ា ព្រះរាជាណាចក្រថៃ។

**៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ចំពោះសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណី៖

• សំណើសុំសាងសង់អគារស្ថានីយ៍សាឡាង នៅទីតាំងកំពង់ចម្លងភ្នំពេញ-អរិយក្សត្រ ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ជាថ្នូរនឹងការទទួលបានសិទ្ធិវិនិយោគជាមួយរដ្ឋបាលរាជធានីភ្នំពេញក្នុងការធ្វើអាជីវកម្មដូចជា កោដនីយដ្ឋាន និងហាងលក់ទំនិញ នៅក្នុងអគារស្ថានីយ៍សាឡាង។

• សំណើសុំជួលរយៈពេលវែងនូវដីទំហំ ៣.០០០ម៉ែត្រការ៉េ ជាប់នឹងគល់ស្ពានកោះពេជ្រត្រើយខាងលិច ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញជូនក្រុមហ៊ុន Ambitious Dragon Investment Limitet (ADIL) ដើម្បីសាងសង់អគារពាណិជ្ជកម្មកម្ពស់ ៦៥ជាន់ និងចំណតរថយន្តក្រោមដី។

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីស្នើសុំគោលការណ៍រៀបចំតំបន់រដ្ឋបាលស្រុកអូររាំងថ្មី ដោយកាត់ដីទំហំ ២១៧,៨៣២ ហិកតា ស្ថិតនៅក្នុងភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។

-រដ្ឋបាលខេត្តស្ទឹងត្រែង ករណីស្នើសុំគោលការណ៍ដោះស្រាយការតាំងទីលំនៅផ្ទះសម្បែងរបស់ប្រជាពលរដ្ឋរស់នៅលើដីចំណីទន្លេក្នុងក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

-រដ្ឋបាលខេត្តបាត់ដំបង ករណីស្នើសុំរៀបចំអនុវត្តគម្រោងដីសម្បទានសង្គមកិច្ចសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយការបាក់ស្រុតច្រាំងស្ទឹងសង្កែ នៅក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង។

-រដ្ឋបាលខេត្តព្រៃវែង ករណីស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តព្រៃវែងនូវទីតាំងដីចាក់សម្រាម ០១កន្លែង និងរថយន្តចំនួន ០២គ្រឿង។

-រដ្ឋបាលខេត្តកំពង់ចាម ករណីស្នើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលសង្កាត់កំពង់ចាម (អតីតសាលាឃុំកំពង់ចាម) ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

-បន្តពិនិត្យ និងលើកយោបល់សំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍរបស់រដ្ឋបាលរាជធានី ខេត្ត ឆ្នាំ ២០១៩ និងឆ្នាំ២០២០។

-បន្តរៀបចំធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍឆ្នាំ ២០១៩ របស់រដ្ឋបាលរាជធានី ខេត្ត ក្នុងអំឡុងពេលកំពុងអនុវត្តគម្រោង។

**៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តអនុវត្តការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាល ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ

-បន្តគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបនូវរបាយការណ៍សកម្មភាព និងការផ្តល់លេខគណនីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានារបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់(APG)

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRP-JG) នៃក្រុមការងារហិរញ្ញវត្ថុ (FATF)

-បូកសរុបរបាយការណ៍លទ្ធផលស្តីពីការរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤ ជូនទៅរាជរដ្ឋាភិបាលដើម្បីសុំគោលការណ៍ដឹកនាំបន្ត។

-បន្តរៀបចំកិច្ចប្រជុំលើកទី៥ ដើម្បីពិនិត្យពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

**៦.៤.២-ការងារគណបក្សនយោបាយ**

-បន្តពិនិត្យ លើកយោបល់ អំពីការសុំបង្កើត ឬការសុំចុះបញ្ជីនិងសំណើនានារបស់គណបក្សនយោបាយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

-បន្តពិនិត្យ លើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនិងការផ្លាស់ប្តូរ ឬការប្រែប្រួលនានារបស់គណបក្សនយោបាយ

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បន្តតាមដានពិនិត្យបូកសរុបប្រមូលព័ត៌មាន ពីគ្រប់បណ្តាញព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈ ច្បាប់ស្តីពីគណបក្សនយោបាយ និង លិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-បន្តពិនិត្យ និងសិក្សាអំពីការធ្វើវិសោធកម្មប្រកាសរួមលេខ ០០៧សហវ.ហ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីអាករចុះបញ្ជីគណបក្សនយោបាយ រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បន្តពិនិត្យ រៀបចំបោះពុម្ពសៀវភៅច្បាប់ស្តីពីគណបក្សនយោបាយ

-ពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានារបស់គណបក្សនយោបាយ

-រៀបចំលិខិតជូនដំណឹងរំលឹកចំពោះគណបក្សនយោបាយចំនួន៦ ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តម្រូវឱ្យបំពេញសំណុំលិខិតឱ្យបានត្រឹមត្រូវ ស្របតាមលក្ខន្តិកៈ និងបទប្បញ្ញត្តមាត្រា២៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ

-រៀបចំបែបបទធ្វើការផាកពិន័យជាប្រាក់ និងផ្អាកសកម្មភាពជាបណ្តោះអាសន្នរយៈពេល១ឆ្នាំ ចំពោះគណបក្សវង្គតខេមរៈមហានគរ ស្របតាមមាត្រា៣៩ថ្មី ដោយសារបានប្រព្រឹត្តល្មើសនឹងមាត្រា៣១ នៃច្បាប់ស្តីពីគណបក្សនយោបាយ ព្រមទាំងធ្វើលិខិតទៅគណបក្សមហាសាមគ្គីជាតិខ្មែរ ស្តីពីការមិនបំពេញកាតព្វកិច្ចក្នុងការបង់ប្រាក់ពិន័យតាមរយៈសេចក្តីសម្រេចលេខ ៥៦៨៨ សសរ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ។

អគ្គនាយក

ប្លាក់ សំរឿន

*ចម្លងជូន៖*

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្តីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*